15

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៩

ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៥

សាលដីកា

លេខ : ០៤

ចុះថ្ងៃ ០៤ ខែមករា ឆ្នាំ១៩៩៦

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ ១៩៩៦ ដោយមានសមាសភាពដូចតទៅ : -

១ - ឯកឧត្តម ចាន់ សុក ជាប្រធាន

២ - លោក ប៉ែន ស៊ុន ជាចៅក្រម

៣ - លោក ទៀល មួន ជាចៅក្រម

៤ - លោក ស៊ុន ឌឹម ជាចៅក្រម

៥ - លោក ឌីវ កេង ជាចៅក្រម

ក្រឡាបញ្ជី លោក ✓ សុង ម៉ៅ

តំណាងមហាអយ្យការលោក ប៉ែន សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៣៥ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៩៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ១៩៩៤របស់ សាលាឧទ្ធរណ៍ ។

ខាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ សួស ណារ៉ាំ ភេទស្រី អាយុ ៣៩ ឆ្នាំសញ្ជាតិកម្ពុជា របររកស៊ី ធ្វើការនៅក្រសួងឃោសនាការ ទីលំនៅផ្ទះលេខ ៣២ ក្រុមទី ៤១ សង្កាត់ ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សួស ផាន់ "ស" ម្តាយឈ្មោះ ម៉ាន់ ពត "ស" ប្តីឈ្មោះ ហ៊ឹម ឆែម ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះ ស្វាយ សុជាតិ ភេទស្រី អាយុ ៣០ ឆ្នាំ សញ្ជាតិ កម្ពុជា របររកស៊ី ធ្វើការនៅខណ្ឌដូនពេញ ទីលំនៅផ្ទះលេខ ៣០ ក្រុម៤១ សង្កាត់ ផ្សារថ្មីទី ៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ស្វាយ វណ្ណី "រស់" ម្តាយ ឈ្មោះ ជៀម ញ៉ី "រស់" ប្តីឈ្មោះ ប៉ុល គំណាង ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ឈ្មោះ សួស ណារ៉ាំ ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៣៥ ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៩ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៥របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០៨.០៦.១៩៨៨ របស់ឈ្មោះ សួស ណារ៉ាំ បានប្តឹងសុំទាមទារ ដីឡូតិ៍លេខ ៣០ផ្លូវ ១៨៤ ក្រុមទី ៤១ សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ ក្រុងភ្នំពេញមក

កាន់កាប់វិញ ដោយអាងហេតុថា ខ្លួនបានកាន់កាប់ដីទំនាស់តាំងពីឆ្នាំ ១៩៧៩មក ក្រោយមកឈ្មោះ ម៉ាន់ ផារិន បានមកសុំខ្លួនស្នាក់នៅលើដីនេះជាបណ្ដោះអាសន្នរង់ចាំចូលធ្វើការក្នុងអង្គភាពណាមួយច្បាស់លាស់សិនប្រាប់តែឈ្មោះនេះលួចលក់ដីនេះទៅអោយឈ្មោះស្វាយ . សុជាតិ នាឆ្នាំ ១៩៨៨ តែដើម្បីបញ្ចប់ទំនាស់ខ្លួនសុខចិត្តទិញដីពីឈ្មោះស្វាយ.សុជាតិ តំលៃ ១០ តម្លឹងមាស ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១១២ ចុះថ្ងៃទី ០១ខែមិថុនាឆ្នាំ ១៩៩២ របស់តុលាការក្រុងភ្នំពេញ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងរបស់ឈ្មោះ សួស.ណារ៉ា ដើមចោទចុះថ្ងៃទី ០៨.០៦.៨៨ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - កិច្ចសន្យាលក់ទិញ ផ្ទាល់មាត់លើដីឡូតិ៍លេខ ៣០ រវាងឈ្មោះ ម៉ាន់.ផារិន និងឈ្មោះ ម៉ាន់.ពត កាលពីឆ្នាំ ១៩៨៤ ត្រូវចាត់ទុកជាមោឃៈ តាមមាត្រាទី ៣៥ នៃក្រិត្យច្បាប់លេខ ៣៨ ចុះថ្ងៃ ២៨.១០.១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ។

៣ - កិច្ចសន្យាលក់-ទិញ ផ្ទះដីឡូតិ៍លេខ ៣០ រវាងឈ្មោះ ឌឹក.សំបូរ និង ឈ្មោះ ស្វាយ.សុជាតិ ចុះថ្ងៃទី ០៥.០៤.៨៨ ត្រូវចាត់ទុកជាមោឃៈ តាមមាត្រាទី ៣៥ នៃក្រឹត្យច្បាប់លេខ៣៨ ចុះថ្ងៃទី ២៨.១០.១៩៨៨ របស់ក្រុមប្រឹក្សារដ្ឋ ។

៤ - ប្រគល់ដីឡូតិ៍លេខ ៣០ក្រុម ៤១ សង្កាត់ផ្សារថ្មី ៣ ខ័ណ្ឌដូនពេញ អោយទៅឈ្មោះសួស.ណារ៉ា ជាកម្មសិទ្ធិ ចាប់តាំងពីពេលនេះតទៅ ។

៥ - បង្គាប់អោយឈ្មោះ ស្វាយ.សុជាតិ និង ក្រុមគ្រួសារចេញពីដីឡូតិ៍លេខ ៣០ ក្រុម ៤១ សង្កាត់ផ្សារថ្មី ៣ ខ័ណ្ឌដូនពេញ ក្នុងរយៈពេល ២០ថ្ងៃ គិតចាប់តាំងពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៦ - សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្តី សំរេចជាលើកទី ១ និងជាលើកចុងក្រោយបង្អស់ ។

បានឃើញបណ្តឹងសាទុក្ខរបស់ប្រធានតុលាការកំពូលលេខ ២២-៩២ សសរតប្រក ចុះថ្ងៃទី ២១.០៩.៩២ លើសាលក្រមរដ្ឋប្បវេណី ១១២ ចុះថ្ងៃទី ០១.០៦.៩២ របស់តុលាការ ក្រុងភ្នំពេញ ត្រង់ចំនុចទាំងមូលនៃសាលក្រម ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៩ ចុះថ្ងៃទី ២១ខែ កញ្ញា ឆ្នាំ ១៩៩៤ របស់សាលាឧទ្ធរណ៍ សំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ : -

១ - សម្រេចទទួលបណ្តឹងឧទ្ធរណ៍ របស់ នាង ស្វាយ.សុជាតិ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - សម្រេចបដិសេធ សាលក្រមរបស់តុលាការក្រុងភ្នំពេញលេខ ១១២ ចុះថ្ងៃទី ០១.០៦.៩២ ចោលជាអសារបង់ ។

៣ - ប្រគល់ចំណែកដីឡូតិ៍លេខ ៣០ ទំហំ ១០ម៉ែត្រគុណ ៣០ម៉ែត្រស្ថិតនៅសង្កាត់ផ្សារ



០៧

ថ្វីទី៣ ឈ្នួលផ្ទូនពេញ អោយទៅឈ្មោះ ស្វាយ.សុជាតិ ។

៤- រីឯសោហ៊ុយប្រាក់ប្រដាប់ក្តី គឺពន្ធហ្វឹង និង ពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីការនិយប្រាក់ ៤៥០រៀល ចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល និង ចំណាយទៅលើដីកាកោះ ៥០០០រៀល សរុប ១៣.១០០រៀល ។ ប្រាក់នេះនាង ស្វាយ.សុជាតិ បានបង់រួចហើយ ហើយ កាលបើផុតរយៈពេលបណ្តឹងសាទុក្ខ បង្គាប់អោយនាង សួស.ណារ៉ា សងប្រាក់ ១៣.០០០រៀល អោយទៅ នាង ស្វាយ.សុជាតិ វិញ និង បង្គាប់អោយនាង សួស.ណារ៉ា បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដី ៣៥តម្លឹងមាសស្មើនិង ៣៥ ហ៊ុន ។

៥- សាលដីកានេះប្រកាសចំពោះគូក្តី សម្រេចបើកផ្លូវសាទុក្ខរយៈពេលពីរខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ របស់ឈ្មោះ សួស.ណារ៉ា ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ ៣៥ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៤របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ឈ្មោះ សួស.ណារ៉ា ។

បានឃើញសារណាតបចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៥ របស់ឈ្មោះស្វាយ.សុជាតិ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍ -

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ :

សាលដីការបស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់តទៅ ។

បានឃើញចម្លើយរបស់ឈ្មោះ សួស.ណារ៉ា ជាដើមចោទ និង ជាដើមបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ខ្ញុំឥតមានយោបល់អីទេ ក្នុងសារណាបានជំរាបសព្វគ្រប់អស់ហើយ។

បានឃើញចម្លើយរបស់ឈ្មោះ ស្វាយ.សុជាតិ ជាចុងចម្លើយ និង ជា ចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយបញ្ជាក់ថា : ខ្ញុំឥតមានយោបល់អ្វីទេ សូមអោយតុលាការកំពូលរកយុត្តិធម៌អោយខ្ញុំផង ។

ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់គូភាគី

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី ១៤.១១.៩៤ របស់អ្នកស្រីសួស.ណារ៉ា ប្តឹងមិនសុខចិត្តនិងសេចក្តីសំរេច របស់សាលាឧទ្ធរណ៍ទាំងមូលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់

ឈាជំរះក្ដី ។

- យល់ឃើញថា: ឈ្មោះ ម៉ាន់.ពត ម្ដាយអ្នកស្រី សួស.ណារ៉ា ពិតជាបានកាន់កាប់ ថែរក្សា និង ដាំដំណាំ លើដីទំនាស់នេះប្រាកដមែន ហើយនៅឆ្នាំ ១៩៨៤ ឈ្មោះ ម៉ាន់.ពត បានលក់ដីមួយចំណែកអោយទៅម៉ាន់.ដារិន ដោយអ្នកស្រី សួស.ណារ៉ា ជាកូនបានដឹងថាឈ្មោះ ម៉ាន់.ដារិន បានប្រគល់ប្រាក់អោយម្ដាយខ្លួនពីដងផង ដូច្នេះឈ្មោះ ម៉ាន់.ដារិន មាន សិទ្ធិ បរិបូរណ៍ ក្នុងការចាត់ចែងដីនេះ ដែលជាហេតុ នាំអោយការលក់-ទិញដីរវាង ឈ្មោះ ម៉ាន់.ដារិន និង ស្វាយ.សុជាតិតាមលិខិតកិច្ចសន្យាចុះថ្ងៃទី ០៥.០៤.៨៨ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ។

- យល់ឃើញថា: សាលដីការដ្ឋប្បវេណីលេខ ៣៥ ចុះថ្ងៃទី ២១.១៩.៨៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិ ច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដី : ចំពោះមុខគូក្ដី

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៤៦ ចុះថ្ងៃទី ១៤.១១.៨៤ របស់អ្នកស្រី សួស.ណារ៉ា ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុស នឹង គតិ ច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣៥ ចុះថ្ងៃទី ២១.០៩.៨៤ របស់សាលាឧទ្ធរណ៍ ទុកជា[illegible]នការពេញទាំងស្រុង ។

៣ - រឹបអូសប្រាក់ប្រដាប់ក្ដីដែលអ្នកស្រី សួស.ណារ៉ា បានបង់ទុកនៅតុលាការកំពូល ចំនួន ១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្ដី និង ពន្ធថ្លឹង ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

-ចំណាយក្នុងការប្រគល់ដីកាកោះ ១២.០០០រៀល សរុប ១៦.០០០រៀលសល់ ៣.០០០រៀល ប្រគល់អោយម្ចាស់ដើមវិញ ។

បង្គាប់អោយអ្នកស្រី សួស.ណារ៉ា បង់ប្រាក់ពន្ធសមាមាត្រ១ភាគរយលើតម្លៃដី ៣៥ តម្លឹង មាស ស្មើនិង ៣៥ ហ៊ុន ។ ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋ ៨០ ភាគរយ និង២០ភាគរយសំរាប់រង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៤ ខែមករា ឆ្នាំ ១៩៨៦ ។